# កំណែទម្រង់ជាប្រព័ន្ធគួរត្រូវបានធ្វើឡើង លើសពីការដោះលែងសកម្មជនសិទ្ធិមនុស្ស ដោយមានលក្ខខណ្ឌ

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

យើងខ្ញុំជាក្រុមសង្គមស៊ីវិលដូចមានរាយនាមខាងក្រោម សូមស្វាគមន៍ចំពោះការដោះលែងសកម្មជនសិទ្ធិមនុស្សច្រើនជាង ២៧ នាក់ ដែលបានជាប់ពន្ធនាគារ និងត្រូវបានផ្តន្ទាទោសដោយអយុត្តិធម៌នាពេលថ្មីៗនេះ និងរីករាយនៅពេលដែលអ្នកទាំងនោះបានជួបជុំគ្រួសាររបស់ពួកគេវិញ ។ ប៉ុន្តែភាគច្រើននៃសកម្មជនទាំងនោះនៅបន្តប្រឈមមុខនឹងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ឬនៅបន្តស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជាមួយលក្ខខណ្ឌដ៏តឹងរ៉ឹងជាច្រើន ដោយគ្រាន់តែអ្នកទាំងនោះអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិសេរីភាពក្នុងការប្រជុំ និងការជួបជុំដោយអហិង្សាតែប៉ុណ្ណោះ ។ មិនមានចំណាត់ការណាមួយ ត្រូវបានធ្វើឡើង ដើម្បីធ្វើការកែទម្រង់ច្បាប់និងប្រព័ន្ធដែលបណ្តាលឱ្យមានការធ្វើទុក្ខបុកម្នេញ និងបំបិទសិទ្ធិសេរីភាព និងរឹតត្បិតការចូលរួមនយោបាយរបស់ពលរដ្ឋនៅកម្ពុជានោះទេ ។

ដោយសកម្មជនជាច្រើន ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ឬត្រូវបានតុលាការព្យួរទោសសាកល្បងរយៈពេលពីរឬបីឆ្នាំ អ្នកទាំងនោះមិនអាចបំពេញការងារក្នុងការការពារសិទ្ធិមនុស្ស ឬបរិស្ថាន ការនិយាយអំពីភាពអយុត្តិធម៌ក្នុងសង្គម ឬចូលរួមក្នុងសកម្មភាពនយោបាយដោយគ្មានការភ័យខ្លាចនឹងការចាប់ខ្លួនបាននោះទេ ។ ការដោះលែងនេះពុំបានសបញ្ជាក់ការពិតដែលសកម្មជនទាំងនោះត្រូវបានផ្តន្ទាទោសដោយមិនត្រឹមត្រូវនោះទេ និងការពិតដែលថាសកម្មជនជាច្រើននាក់ត្រូវបានចាប់ឃុំខ្លួនអស់រយៈជាងមួយឆ្នាំកន្លងមក នៅក្នុងពន្ធនាគារដ៏ចង្អៀតណែន ដោយក្នុងចំណោមពួកគេម្នាក់បាននិយាយថាកន្លែងនោះជា "ឋាននរក" ។

លើសពីនេះទៅទៀត មនុស្សច្រើនជាង ៦០នាក់ផ្សេងទៀត ដែលរួមមាន អ្នកសារព័ត៌មាន សកម្មជននយោបាយ អ្នកប្រើប្រាស់បណ្តាញសង្គម និងសកម្មជនដីធ្លីជាង ១០នាក់ទៀតនោះ កំពុងតែជាប់ពន្ធនាគារដោយសារការងារ និងភាពសកម្មនិយមរបស់ពួកគេ ។ ការចោទប្រកាន់ពីបទញុះញង់ និងបទរួមគំនិតក្បត់នៅតែត្រូវបានគេប្រើប្រាស់ ទៅលើជនណាដែលហ៊ាននិយាយតវ៉ា ឬរិះគន់ទៅលើអាជ្ញាធររដ្ឋ ហើយភាពញឹកញាប់នៃការប្រើប្រាស់វិធីសាស្ត្រខាងលើនិងការកើនឡើងនៃការត្រួតពិនិត្យចាប់ពិរុទ្ធខ្លួនឯង គឺជាការគំរាមកំហែងមួយដែលកំពុងកើនឡើង ។

ការដោះលែងទាំងនេះមិនអាចជំនួសកំណែទម្រង់ជាមូលដ្ឋានទៅលើច្បាប់ និងស្ថាប័ននានានៅប្រទេសកម្ពុជានោះទេ ។ ប្រជាពលរដ្ឋកម្ពុជានៅតែបន្តប្រឈមនឹងការរឹតត្បិតជាបន្តបន្ទាប់ ទៅលើសិទ្ធិសេរីភាពក្នុងការចូលរួមដោយសេរីក្នុងជីវិតនយោបាយ និងការជ្រើសរើសអ្នកដឹកនាំរបស់ពួកគេ ។ គណបក្សសង្គ្រោះជាតិត្រូវបានគេរំលាយ គណបក្សដទៃទៀតត្រូវបានគេបដិសេធសិទ្ធិក្នុងការបង្កើត ហើយគណបក្សទាំងអស់ត្រូវស្ថិត

ក្រោមការសម្រេចចិត្តរបស់តុលាការ និងក្រសួងមហាផ្ទៃដែលមានសិទ្ធិអំណាចត្រួតពិនិត្យនិងសម្រេចថាតើគណបក្សទាំងនោះអាចប្រកួតប្រជែងក្នុងការបោះឆ្នោតនាពេលខាងមុខនេះបានឬទេ ។

សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា នៅតែបន្តស្ថិតក្រោមការគំរាមគំហែងឥតឈប់ឈរពីប្រព័ន្ធតុលាការដែលលម្អៀងផ្នែកនយោបាយ និងច្បាប់ដែលមានលក្ខណៈគាបសង្កត់ ។ ច្បាប់ទាំងនេះរួមមានវិសោធនកម្មរដ្ឋធម្មនុញ្ញចុងក្រោយ វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនិងច្បាប់ស្តីពីការបោះឆ្នោត ក៏ដូចជាច្បាប់សហជីព ច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីការការពារជំងឺកូវីត-១៩ ច្បាប់ស្តីពីទូរគមនាគមន៍ និងអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ។ វិសោធនកម្មច្បាប់ និងច្បាប់ថ្មីៗទាំងនេះ គួរតែបានលុបចោលដើម្បីស្តារលំហសេរីភាពរបស់ពលរដ្ឋ និងសេរីភាពនយោបាយនៅក្នុងប្រទេសឡើងវិញ ។

យើងខ្ញុំសូមអបអរសាទរលើការដោះលែងសកម្មជនទាំងនេះ ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ថា ការដោះលែងដោយមានលក្ខខណ្ឌមិនអាចដោះស្រាយភាពអយុត្តិធម៌ជាប្រព័ន្ធដែលអ្នកទាំងនោះបានលើកឡើងជាសាធារណៈមុនពេលមានការចាប់របស់ពួកគេនោះទេ ហើយក៏សូមបញ្ជាក់ដែរថាទោះជាពួកគេត្រូវបានដោះលែងក៏ដោយ ក៏អ្នកទាំងនោះនិងអ្នកដទៃទៀតនៅតែបន្តស្ថិតក្រោមការគំរាមគំហែងដដែល ។ យើងខ្ញុំស្នើដល់អាជ្ញាធរ មេត្តាចាត់វិធានការជាប្រព័ន្ធដើម្បីស្តារលទ្ធិប្រជាធិបតេយ្យ និងលំហសេរីភាពរបស់ពលរដ្ឋក្នុងប្រទេសឡើងវិញ ហើយនិងស្តារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាពលរដ្ឋឡើងវិញទាំងអស់ មុនពេលការឈានមកដល់នៃការបោះឆ្នោតខាងមុខ ។ ជាងនេះទៅទៀត យើងខ្ញុំសូមស្នើដល់អាជ្ញាធរ មេត្តាដោះលែងអ្នកទោសនយោបាយ និងសកម្មជនទាំងអស់ ដែលត្រូវបានចោទប្រកាន់ដោយសារការអនុវត្តសិទ្ធិមូលដ្ឋានរបស់ពួកគេ ហើយសូមទម្លាក់ចោលការចោទប្រកាន់ទាំងអស់ពីសកម្មជនទាំងនោះ ៕

**អង្គការ សមាគម សហជីព សហគមន៍ ដែលចូលរួមគាំទ្រសេចក្តីថ្លែងការណ៍៖**

១. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
២. សហគមន៍អមលាំង (កំពង់ស្ពឺ)
៣. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
៤. សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ (AEC)
៥. សហគមន៍ជនជាតិដើមភាគតិចអារ៉ែង (កោះកុង)
៦. សហគមន៍បឹងប្រាំ (បាត់ដំបង)
៧. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
៨. អង្គការព្រះពុទ្ធសាសនាសម្រាប់សន្តិភាព (BPO)
៩. សម្ព័ន្ធសហជីពកម្ពុជា (CATU)
១០. សហភាពការងារកម្ពុជា (CLC)

១១. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១២. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៤. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
១៥. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
១៦. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
១៧. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
១៨. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
១៩. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
២០. បណ្តាញយុវជនកម្ពុជា (CYN)
២១. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
២២. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
២៣. សហគមន៍ដីធ្លីជីខលើ (កោះកុង)
២៤. សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ (រតនគិរី)
២៥. សហគមន៍ជាំក្រវៀន (ត្បូងឃ្មុំ)
២៦. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
២៧. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
២៨. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
២៩. បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
៣០. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
៣១. សហគមន៍ដកពរ (កំពង់ស្ពឺ)
៣២. អង្គការសមធម៌កម្ពុជា (EC)
៣៣. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
៣៤. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
៣៥. បណ្តាញព្រះសង្ឃ ឯករាជ្យដើម្បីយុត្តិធម៌សង្គម (IMNSJ)
៣៦. សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)
៣៧. សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)
៣៨. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
៣៩. សហគមន៍នេសាទកោះស្រឡៅ (កោះកុង)
៤០. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើល
៤១. សហគមន៍ដីធ្លីខេត្តប៉ៃលិន

៤២. សហគមន៍ឡពាង (កំពង់ឆ្នាំង)
៤៣. សហគមន៍មានជ័យ (ស្វាយរៀង)
៤៤. អង្គការស្ពានសន្តិភាព (PBO)
៤៥. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)
៤៦. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
៤៧. អង្គការពន្លកខ្មែរ (PKH)
៤៨. សហគមន៍ដីធ្លីព្រែកខ្សាច់ (កោះកុង)
៤៩. សហគមន៍ដីធ្លីព្រៃពាយ (កំពត)
៥០. សហគមន៍ព្រៃឈើពេជ្រចង្វារល្អឆើត (កំពង់ឆ្នាំង)
៥១. សហគមន៍ព្រៃឡង់ (កំពង់ធំ)
៥២. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
៥៣. អង្គការសមាគមធាងត្នោត (សធត)
៥៤. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
៥៥. សហគមន៍សាមគ្គីរមាសហែក (ស្វាយរៀង)
៥៦. សហគមន៍សាមគ្គីសង្កែពីរមានរឹទ្ធិ (ព្រះវិហារ)
៥៧. សហគមន៍ព្រៃឈើទេសចរណ៍ទឹកធ្លាក់ស្រែអំពិល (កំពង់ឆ្នាំង)
៥៨. សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
៥៩. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
៦០. សហគមន៍ដីធ្លីតានី (សៀមរាប)
៦១. សហគមន៍ដីធ្លីតានូន (កោះកុង)
៦២. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
៦៣. សហគមន៍ទន្លូង (ត្បូងឃ្មុំ)
៦៤. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
៦៥. អង្គការតម្លាភាពកម្ពុជា (TIC)
៦៦. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)